**សុន្ទរកថារបស់ លោក ជីបា តាយហ្សូ**
**លេខាទី២ ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា**
**ថ្លែងក្នុងពិធីសម្ពោធដាក់អោយប្រើប្រាស់ស្ពានដងទង់ ក្នុងស្រុកសំរោង ខេត្តឧត្តរមានជ័យ**
ថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៧

- **សូមគោរព ឯកឧត្តម ស ថាវី អភិបាលនៃគណៈអភិបាលខេត្តឧត្តរមានជ័យ**
- **សូមគោរព ឯកឧត្តម យឹម ធិន ប្រធានក្រុមប្រឹក្សាខេត្តឧត្តរមានជ័យ**
- **សូមគោរព លោក សាំង ប៊ុនថេន ប្រធានមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្តឧត្តរមានជ័យ**
- **សូមគោរព អស់លោក លោកស្រី!**

ថ្ងៃនេះខ្ញុំសប្បាយចិត្តណាស់ ដែលបានមកចូលរួមក្នុងពិធីសម្ពោធស្ពានបេតុងដងទង់ ក្នុងស្រុកសំរោង ខេត្តឧត្តរមានជ័យ ជាមួយវត្តមានរបស់ **ឯកឧត្តម ស៖ ថាវី** អភិបាលនៃគណៈអភិបាលខេត្តឧត្តរមានជ័យ និង **ឯកឧត្តម យឹម ធិន** ប្រធានក្រុមប្រឹក្សាខេត្តឧត្តរមានជ័យ ។

ការកែលម្អហេដ្ឋារចនាសម្ព័ន្ធ គឺជាវិស័យអាទិភាពមួយនៃកិច្ចសហប្រតិបត្តិការរបស់ជប៉ុនសម្រាប់កម្ពុជា ហើយជាក់ស្តែងគម្រោងកែលម្អហេដ្ឋារចនាសម្ព័ន្ធជាច្រើន ត្រូវបានអនុវត្តនៅតាមទីជនបទ។ ឥឡូវនេះ ខ្ញុំសប្បាយរីករាយណាស់ ដែលបានមកឃើញស្ពានបេតុងថ្មីនេះ ក្រោមជំនួយគូសាណូណិ។

ខ្ញុំទទួលស្គាល់ថា ការសាងសង់ស្ពានបេតុងថ្មីនេះ នឹងផ្តល់អត្ថប្រយោជន៍ដល់ប្រជាជនប្រមាណ៣,៤០០នាក់ដែលរស់នៅក្នុងតំបន់នេះ។ គម្រោងនេះ នឹងផ្តល់ភាពងាយស្រួលជាងមុនដល់ប្រជាជនក្នុងការធ្វើដំណើរទៅកាន់សាលារៀន មន្ទីរពេទ្យ ផ្សារ និងលើកស្ទួយការដឹកជញ្ជូនកសិផលផងដែរ។

ខ្ញុំសង្ឃឹមថាមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្តឧត្តរមានជ័យ នឹងថែទាំស្ពានបេតុងនេះឲ្យបានល្អ ដើម្បីអោយប្រជាជនទាំងអស់ អាចទទួលបានអត្ថប្រយោជន៍យូរអង្វែង។

ជាចុងក្រោយនេះ ខ្ញុំសូមសម្តែងការកោតសរសើរចំពោះលោក-អ្នកទាំងអស់ ដែលបានរួមចំណែកធ្វើឲ្យការអនុវត្តគម្រោងនេះប្រព្រឹត្តទៅបានយ៉ាងរលូន។ ខ្ញុំសង្ឃឹមយ៉ាងមុតមាំថាស្ពានបេតុងនេះ នឹងក្លាយជានិមិត្តរូបនៃមិត្តភាពរវាងប្រទេសយើងទាំងពីរ និងជួយពង្រឹងជាបន្តនូវទំនាក់ទំនងមិត្តភាពរវាងប្រជាជនជប៉ុន និងប្រជាជនកម្ពុជា៕

**សូមអរគុណ!**